# ព្រះរាជក្រម

នស/រកម/១១១៧/០១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
## ស្ដីពី
## ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយ ចំនួនទៀតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះរវាងសមាគម ប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)និង សាធារណរដ្ឋប្រជាមានិតចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្ទុកលើនីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម.១១១៧.០៤៤

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ហត្ថលេខា**
**ប៉ាន សូរស័ក្ដិ**

លេខ ១០៦១ស.ណ
**សំណៅ[illegible]ជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible] សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧- សព្រ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៥

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

ប្រទានសិទ្ធិជូនឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា ដើម្បីចុះហត្ថលេខាលើពិធីសារដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួន រវាងរដ្ឋាភិបាលប្រទេសសមាជិកអាស៊ាន និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ។

ក្នុងករណី ឯកឧត្តម **ស៊ុន ចាន់ថុល** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន ។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ ។

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

រាជរដ្ឋាភិបាល
*Royal Government*
N° 67-D.F.P

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

*Phnom Penh, November 18 2015*

## DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia,
- Having seen the Royal Degree NS/RKT/0913/903 dated 24 September 2013 on the Nomination of the Royal Government of Cambodia,
- Having seen the Royal Degree No. 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers,
- Having seen the Royal Kram NS/RKM/0196/16 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Commerce,
- Pursuant to the Proposal of the Minister of Commerce.

## THE ROYAL GOVERNMENT

Delegates herewith Full Power to H.E. Mr. SUN CHANTHOL, Senior Minister, Minister of Commerce and ASEAN Economic Minister for Cambodia, to sign **the Protocol to Amend the Framework Agreement on Comprehensive Economic Co-operation and Certain Agreements thereunder between the Association of Southeast Asian Nations (ASEAN) and the People's Republic of China.**

This power includes the power of delegation.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed the Delegation of Full Powers.

PRIME MINISTER

Samdech Akka Moha Sena Padei Techo HUN SEN

# ពិធីសារ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌ
# ស្តីពី
# កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតក្រោម
# កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ
# រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (បន្ទាប់ពីនេះទៅ ហៅជារួមថា «បណ្តាប្រទេសសមាជិកអាស៊ាន» ឬ ហៅដោយឡែកថា«ប្រទេសសមាជិកអាស៊ាន») និងសាធារណរដ្ឋប្រជាមានិតចិន (បន្ទាប់ពីនេះទៅ ហៅថា «ប្រទេសចិន») បន្ទាប់ពីនេះទៅ ហៅរួមថា «បណ្តាភាគី» ឬ ហៅដោយឡែកថា «ភាគី»។

**ដោយរំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន (បន្ទាប់ពីនេះទៅហៅថា "**កិច្ចព្រមព្រៀងក្របខ័ណ្ឌ**") ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**ដោយរំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ (បន្ទាប់ពីនេះទៅហៅថា «**កិច្ចព្រមព្រៀងទំនិញ**») ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ។

**ដោយរំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ (បន្ទាប់ពីនេះទៅហៅថា «**កិច្ចព្រមព្រៀងសេវា**») ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៧ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន។

**ដោយរំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងស្តីពីវិនិយោគនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ (បន្ទាប់ពីនេះទៅហៅថា "**កិច្ចព្រមព្រៀងវិនិយោគ**") ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៩ នៅទីក្រុងបាងកក ប្រទេសថៃ។

**ដោយរំលឹកឡើងវិញ** នូវសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំកំពូលអាស៊ាន-ចិនលើកទី១៦ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៣ ដែលបានកត់សម្គាល់អំពីតួនាទីជាវិជ្ជមាន នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន



ក.!

(ACFTA) ក្នុងការដើរតួនាទីជំរុញទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្ម និងស្វាគមន៍គំនិតផ្តួចផ្តើមបង្កើនកម្រិតនៃ ACFTA ដោយធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌទីផ្សារ និងគុណភាពពាណិជ្ជកម្ម នៅក្នុងចំណោមបណ្តាភាគីទាំងអស់ ព្រមទាំងពង្រីកវិសាលភាព និង លទ្ធភាពគ្របដណ្តប់លើកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ។

**ដោយប្រាថ្នា** ចង់ធ្វើឱ្យ ACFTA មានភាពប្រសើរឡើង ដើម្បីឆ្លើយតបឱ្យបានកាន់តែល្អជាងមុនទៅនឹងការវិវត្តនិម្មាបនកម្មសេដ្ឋកិច្ចសកល តាមរយៈការបញ្ជាក់សារជាថ្មីនៃការប្តេជ្ញាចិត្ត និងធ្វើឱ្យការតភ្ជាប់សេដ្ឋកិច្ចរវាងអាស៊ាន និងចិនកាន់តែមានភាពស៊ីជម្រៅ តាមរយៈការបន្តធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញ និងពាណិជ្ជកម្មសេវា វិធានប្រភពដើមទំនិញ ដែលជួយសម្រួលដល់ពាណិជ្ជកម្មបន្ថែមទៀត នីតិវិធីគយ និងវិធានការសម្រួលពាណិជ្ជកម្មប្រសើរជាងមុន ការធ្វើសេរីភាវូបនីយកម្មការវិនិយោគ កិច្ចការពារ ការជំរុញ និងការសម្រួលការវិនិយោគដែលប្រសើរជាងមុន កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដែលល្អប្រសើរ។

**ដោយជឿជាក់ថា** ការបង្កើនកម្រិតនៃ ACFTA នឹងរួមចំណែកដល់ការធ្វើអោយប្រសើរឡើងនូវភាពស៊ីជម្រៅ និងការពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់ពាណិជ្ជកម្ម សេវាកម្ម និងការវិនិយោគ ក្នុងចំណោមបណ្តាភាគីទាំងអស់។

បានព្រមព្រៀងដូចខាងក្រោម:

## ជំពូក ១

## ការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ

### ផ្នែក ក: វិធានប្រភពដើមទំនិញ

ឧបសម្ព័ន្ធ៣ ស្តីពីវិធានប្រភពដើមទំនិញនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នឹងត្រូវដាក់ជំនួសដោយឧបសម្ព័ន្ធ១ នៃពិធីសារនេះ។

### ផ្នែក ខ: នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម (CPTF)

ផ្នែកស្តីពីនីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្មនេះ នឹងត្រូវដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ៖

## មាត្រា ១

## គោលបំណង

គោលបំណងនៃផ្នែកនេះគឺ៖

ក. ធានាឱ្យបាននូវភាពអាចព្យាករបាន សង្គតិភាព និងតម្លាភាពនៃការអនុវត្តច្បាប់គយនៃបណ្តាភាគី
ខ. លើកកម្ពស់ប្រសិទ្ធិភាព ការសន្សំសំចៃផ្នែករដ្ឋបាលនៃនីតិវិធីគយ និងការបញ្ចេញទំនិញរហ័ស
គ. ធ្វើឱ្យមានភាពងាយស្រួល និងសុខដុមនីយកម្មនីតិវិធីគយតាមលទ្ធភាពដែលអាចធ្វើទៅបាន និង
ឃ. ជំរុញកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយនៃបណ្តាភាគីទាំងអស់។

## មាត្រា ២

## វិសាលភាព

យោងទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់បណ្តាភាគី ផ្នែកនេះអនុវត្តចំពោះនីតិវិធីគយសម្រាប់ទំនិញដែលត្រូវបានជួញដូរ និងចរាចរ តាមមធ្យោបាយដឹកជញ្ជូននៅក្នុងចំណោមបណ្តាភាគី។

## មាត្រា ៣

## និយមន័យ

គោលបំណងនៃផ្នែកនេះគឺ៖

រដ្ឋបាលគយ មានន័យថា៖

ក. ចំពោះចិន អគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន និង
ខ. ចំពោះអាស៊ាន រដ្ឋបាលគយនៃប្រទេសជាសមាជិកនីមួយៗ និង/ឬ អាជ្ញាធរមានសមត្ថកិច្ច[១] ដែលទទួលខុសត្រូវអាស្រ័យការកំណត់ដោយច្បាប់នៃភាគីនោះ ដើម្បីគ្រប់គ្រងលើច្បាប់គយ។

ច្បាប់គយ មានន័យថា ច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការនាំចូល នាំចេញ ចរាចរ ឬការស្តុកទំនិញ ការគ្រប់គ្រង និងការអនុវត្ត ដែលជាបន្ទុករបស់រដ្ឋបាលគយ និងបទប្បញ្ញត្តិនានាដែលបង្កើតឡើងដោយរដ្ឋបាលគយក្រោមអំណាចនៃរដ្ឋបាលគយនោះ។

---
១ បញ្ជីអាជ្ញាធរមានសមត្ថកិច្ច និងការកែប្រែណាមួយនាពេលអនាគត គួរជូនដំណឹងទៅបណ្តាភាគីអោយបានទាន់ពេល

នីតិវិធីគយ សំដៅដល់ប្រព្រឹត្តកម្មដែលអនុវត្តដោយរដ្ឋបាលគយនៃភាគីទៅលើទំនិញនិងមធ្យោបាយដឹកជញ្ជូន ដែលជាកម្មវត្ថុនៃច្បាប់គយរបស់ភាគីនោះ។

កិច្ចព្រមព្រៀងកំណត់តម្លៃពន្ធគយ សំដៅដល់កិច្ចព្រមព្រៀងក្នុងការអនុវត្តមាត្រា៧ នៃកិច្ចព្រមព្រៀងទូទៅស្ដីពីអត្រាពន្ធ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ (General Agreement on Tariff and Trade 1994) ដែលមានក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។

មធ្យោបាយដឹកជញ្ជូន សំដៅទៅលើប្រភេទនៃជលយាន យានយន្ត អាកាសយាន និងសត្វពាហនៈដែលដឹកជញ្ជូនទាំងឡាយណាដែលចូលទៅ ឬចាកចេញពីដែនដីនៃភាគីជាអ្នកដឹកជញ្ជូនទំនិញ ឬវត្ថុផ្សេងៗដែលអាចអនុវត្តបានក្រោមច្បាប់ និងបទប្បញ្ញត្តិនៅក្នុងស្រុករបស់ភាគីនីមួយៗ។

## មាត្រា ៤

## កិច្ចសម្រួល

១. ភាគីនីមួយៗត្រូវធានាឱ្យបានថានីតិវិធីគយ និងការអនុវត្តរបស់ខ្លួនអាចព្យាករបាន មានសង្គតិភាព មានតម្លាភាព និងមានភាពសម្រួលដល់ពាណិជ្ជកម្ម រួមបញ្ចូលទាំងការបញ្ចេញទំនិញរហ័ស។

២. នីតិវិធីគយរបស់ភាគីនីមួយៗ ត្រូវអនុលោមតាមលិខិតុបករណ៍ពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងតាមការអនុវត្តដែលផ្ដល់អនុសាសន៍ដោយអង្គការគយពិភពលោក ដែលភាគីនោះជាភាគីហត្ថលេខី តាមលទ្ធភាពដែលអាចធ្វើទៅបាន និងក្នុងកម្រិតដែលអនុញ្ញាតដោយច្បាប់គយ។

៣. រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញនូវនីតិវិធីគយរបស់ខ្លួនដើម្បីសម្រួលពាណិជ្ជកម្ម។

៤. ការត្រួតពិនិត្យរបស់គយ ត្រូវបានកម្រិតត្រឹមកម្រិតអ្វីដែលចាំបាច់ដើម្បីធានាឱ្យស្របតាមច្បាប់គយរបស់សាមីភាគី។

## មាត្រា ៥

## កិច្ចសហប្រតិបត្តិការគយ

ក្នុងកម្រិតដែលត្រូវបានអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវសហការជាមួយនឹងរដ្ឋបាលគយរបស់ភាគីដទៃទៀតទៅតាមការចាំបាច់ ដែលពាក់ព័ន្ធនឹង៖

ក. ការអនុវត្ត និងដំណើរការក្នុងជំពូកនេះ

ខ. បញ្ហាផ្សេងៗ ដូចដែលបណ្ដាភាគីកំណត់រួមគ្នា។

## មាត្រា ៦

## ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម

១. រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវខិតខំបង្កើតឱ្យមានប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ខ្លួនមួយដែលអាចទ្រទ្រង់បាននូវប្រតិបត្តិការគយតាមអេឡិចត្រូនិច តាមតែអាចអនុវត្តទៅបាន ។

២. ក្នុងការអនុវត្តគំនិតផ្តួចផ្តើម រដ្ឋបាលគយរបស់ភាគីនីមួយៗ ត្រូវរៀបចំស្តង់ដារដែលពាក់ព័ន្ធ និងការអនុវត្តល្អបំផុតដែលជាអនុសាសន៍អង្គការគយពិភពលោក ដោយពិនិត្យពិចារណាតាមកម្រិតហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពដែលអាចធ្វើទៅបានរបស់ភាគីនីមួយៗ។

## មាត្រា ៧

## ការកំណត់តម្លៃពន្ធគយ

បណ្តាភាគីត្រូវអនុវត្តមាត្រា៧ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងលើការកំណត់តម្លៃពន្ធគយចំពោះទំនិញដែលត្រូវបានជួញដូរក្នុងចំណោមបណ្តាភាគី។

## មាត្រា ៨

## ចំណាត់ថ្នាក់ទំនិញ

បណ្តាភាគីត្រូវអនុវត្តនូវអនុសញ្ញាអន្តរជាតិស្តីពីប្រព័ន្ធសុខដុមនីយកម្មលេខកូដ និងបរិយាយចំណាត់ថ្នាក់ទំនិញ (International Convention on the Harmonized Commodity Description and Coding System) ចំពោះទំនិញដែលត្រូវបានជួញដូរក្នុងចំណោមបណ្តាភាគី។

## មាត្រា ៩

## ការគ្រប់គ្រងហានិភ័យ

១. បណ្តាភាគីត្រូវប្រើប្រាស់ការគ្រប់គ្រងហានិភ័យ ដើម្បីកំណត់វិធានការក្នុងការត្រួតពិនិត្យក្នុងគោលដៅដើម្បីសម្រួលពាណិជ្ជកម្មស្របច្បាប់ និងពន្លឿនការបញ្ចេញទំនិញពីគយឱ្យបានឆាប់រហ័ស។

២. រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវត្រួតពិនិត្យជាប្រចាំនូវសកម្មភាព និងប្រសិទ្ធិភាពនៃប្រព័ន្ធនេះ ក្នុងការអនុវត្តការគ្រប់គ្រងហានិភ័យចំពោះការត្រួតពិនិត្យគយ។

## មាត្រា ១០

## វិធានកំណត់មុន

១. ភាគីនីមួយៗ ត្រូវផ្តល់នូវវិធានកំណត់មុនពាក់ព័ន្ធចំពោះចំណាត់ថ្នាក់ទំនិញ និងប្រភពដើមទំនិញជាលាយលក្ខណ៍អក្សរ តាមរយៈរដ្ឋបាលគយ ទៅតាមកម្រិតអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក លើការស្នើសុំរបស់បុគ្គលនោះដូចដែលបានចែងក្នុងកថាខណ្ឌ ៣(ក)។

២. បន្ថែមទៅលើកថាខណ្ឌទី១ បណ្តាភាគីត្រូវបានលើកទឹកចិត្តក្នុងការផ្តល់វិធានកំណត់មុន ស្តីពីវិធីសាស្ត្រ និងលក្ខខណ្ឌសមស្រប និងរបៀបប្រើប្រាស់ ដើម្បីកំណត់តម្លៃពន្ធគយទៅតាមស្ថានការណ៍ជាក់ស្តែង។

៣. យោងតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ភាគីនីមួយៗត្រូវប្រើ ឬរក្សានូវនីតិវិធីសម្រាប់វិធានកំណត់មុនដែលត្រូវ៖

(ក) អនុញ្ញាតឱ្យអ្នកនាំចូល អ្នកនាំចេញ ឬ ផលិតករ ដែលត្រូវបានផ្តល់សិទ្ធិដោយភាគី ស្នើសុំវិធានកំណត់មុន មុនពេលនាំចូលទំនិញដែលជាកម្មវត្ថុនៃការស្នើសុំ

(ខ) តម្រូវឱ្យអ្នកស្នើសុំវិធានកំណត់មុន ផ្តល់នូវការបរិយាយលម្អិតនៃមុខទំនិញ និងព័ត៌មានពាក់ព័ន្ធទាំងអស់ដែលចាំបាច់ដើម្បីធានាដល់ការចេញវិធានកំណត់មុន។

(គ) អនុញ្ញាតឱ្យរដ្ឋបាលគយ ស្នើឱ្យអ្នកស្នើសុំផ្តល់នូវព័ត៌មានបន្ថែម ក្នុងកំលុងពេលជាក់លាក់មួយនៅចន្លោះពេលនៃដំណាក់កាលនៃការវាយតម្លៃពាក្យស្នើសុំវិធានកំណត់មុន។

(ឃ) កំណត់ឱ្យផ្តល់វិធានកំណត់មុនណាក៏ដោយ ត្រូវផ្អែកលើស្ថានភាពជាក់ស្តែង និងកាលៈទេសៈដែលផ្តល់ឱ្យដោយអ្នកស្នើសុំ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលជាកម្មវត្ថុសម្រាប់អ្នកចេញសេចក្តីសម្រេច និង

(ង) កំណត់ឱ្យផ្តល់វិធានកំណត់មុនជូនដល់អ្នកស្នើសុំ ឱ្យបានឆាប់រហ័ស នៅពេលដែលទទួលបានព័ត៌មានចាំបាច់គ្រប់គ្រាន់ទាំងអស់រួចហើយ។

៤. ភាគីអាចបដិសេធសំណើស្នើសុំធ្វើវិធានកំណត់មុន នៅពេលដែលសំណើសុំព័ត៌មានបន្ថែមមិនអាចផ្តល់ជូន ក្នុងកំលុងពេលជាក់លាក់មួយ យោងទៅតាមកថាខណ្ឌ ៣(គ) នៃមាត្រានេះ

៥. យោងទៅលើកថាខណ្ឌទី១ និងទី៦ ភាគីនីមួយៗត្រូវអនុវត្តវិធានកំណត់មុនចំពោះការនាំចូលទំនិញទាំងអស់ ដែលបានបរិយាយនៅក្នុងវិធានកំណត់មុននោះ ក្នុងរយៈពេល៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញវិធានកំណត់មុន ឬរយៈពេលផ្សេងពីនេះ អាស្រ័យទៅតាមច្បាប់ និងបទបញ្ញាក្នុងស្រុក

៦. ភាគីអាចកែតម្រូវ ឬលុបចោលវិធានកំណត់មុនបាន ៖

(ក) ដោយសេចក្តីសម្រេចវិធានកំណត់មុននោះមានមូលដ្ឋានលើកំហុសឆ្គងនៃអង្គហេតុ ឬអង្គច្បាប់ ឬព័ត៌មានដែលមិនត្រឹមត្រូវ ឬមិនជាក់លាក់ ។

(ខ) ប្រសិនបើមានការផ្លាស់ប្តូរនៅក្នុងច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ដែលមានជាប់ទាក់ទងជាមួយកិច្ចព្រមព្រៀងនេះ ឬ

(គ) ប្រសិនបើមានការផ្លាស់ប្តូរ ក្នុងធាតុផ្សំអង្គហេតុ ឬកាលៈទេសៈដែលវិធានកំណត់មុនមានមូលដ្ឋានលើ។

៧. ភាគីនីមួយៗអាចចេញផ្សាយវិធានកំណត់មុនរបស់ខ្លួន ដោយយោងទៅលើតម្រូវការការសម្ងាត់វិជ្ជាជីវៈនៃច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ភាគីនោះ។

៨. រដ្ឋបាលគយអាចវាយតម្លៃភាពជាក់ស្តែង និងកាលៈទេសៈនៃការនាំចូល ដែលមានសង្គតិភាពជាមួយនឹងភាពជាក់ស្តែង និងកាលៈទេសៈដរាបណាអ្នកនាំចូលធានាថា ប្រព្រឹត្តកម្មទៅលើទំនិញនាំចូលត្រូវបានគ្របដណ្តប់ដោយវិធានកំណត់មុននោះ។

## មាត្រា ១១

## ការត្រួតពិនិត្យឡើងវិញ និងការសុំឱ្យវិនិច្ឆ័យសារជាថ្មី

១. យោងទៅតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ភាគីនីមួយៗចាំបាច់ត្រូវស្នើការត្រួតពិនិត្យរដ្ឋបាល លើសេចក្តីសម្រេច អ្នកនាំចូល អ្នកនាំចេញ ឬ បុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹងវិធានការរដ្ឋបាល ការកំណត់ ឬ សេចក្តីសម្រេច ត្រូវទទួលបាននូវ៖

ក) ការត្រួតពិនិត្យឡើងវិញនៃផ្នែករដ្ឋបាលលើការកំណត់នានាសម្រេចដោយរដ្ឋបាលគយ ក្នុងកម្រិតមួយដែលឯករាជ្យពីមន្ត្រី ឬការិយាល័យទទួលបន្ទុកសេចក្តីសម្រេច ដែលស្ថិតក្រោមការស្នើសុំពិនិត្យឡើងវិញនោះ។ កម្រិតនៃការត្រួតពិនិត្យឡើងវិញនៃរដ្ឋបាលអាចរួមបញ្ចូលនូវអាជ្ញាធរ ដែលគ្រប់គ្រងរដ្ឋបាលគយ ដោយផ្អែកទៅលើបទប្បញ្ញត្តិក្នុងស្រុក។

ខ) ស្នើត្រួតពិនិត្យឡើងវិញដោយស្ថាប័នតុលាការលើសេចក្តីសម្រេចផ្នែករដ្ឋបាល យោងទៅតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក

២. សេចក្តីសម្រេចលើការត្រួតពិនិត្យឡើងវិញ និង/ឬ ការសុំឱ្យវិនិច្ឆ័យសារជាថ្មីត្រូវផ្តល់ជូនទៅអ្នកដាក់ពាក្យបណ្តឹង ដោយផ្អែកទៅតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់បណ្តាភាគី ហើយហេតុផលនៃការចេញសេចក្តីសម្រេចនេះនឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

## មាត្រា ១២

## ការត្រួតពិនិត្យឡើងវិញនៃនីតិវិធីគយ

នៅក្រោមយន្តការនៃគណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ភាគីនីមួយៗចាំបាច់ត្រូវត្រួតពិនិត្យដោយសាមយិកនូវការអនុវត្តជំពូកនៃនីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្មរួមជាមួយទស្សនវិស័យក្នុងការបន្តការធ្វើឱ្យមានភាពងាយស្រួល និងសុខដុមនីយកម្មនៃនីតិវិធីគយ តាមកម្រិតដែលអាចធ្វើទៅបាន និងការបង្កើតកិច្ចព្រមព្រៀងដែលមានផលប្រយោជន៍ទៅវិញទៅមក (mutually beneficial arrangements) ដើម្បីសម្រួលពាណិជ្ជកម្មរវាងបណ្តាភាគីទាំងអស់។ អនុគណៈកម្មាធិការស្តីពីនីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្មអាចត្រូវបានបង្កើតឡើង និងកោះប្រជុំតាមការចាំបាច់។

## មាត្រា ១៣

## ការបោះពុម្ពផ្សាយ និងកន្លែងសាកសួរព័ត៌មាន

១. ភាគីនីមួយៗ ត្រូវផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណែត និង/ឬ នៅក្នុងទម្រង់នៃការបោះពុម្ពនូវច្បាប់និងបទប្បញ្ញត្តិ និងនីតិវិធីរដ្ឋបាលគយនានា ដែលត្រូវបានអនុវត្ត ឬពង្រឹងដោយរដ្ឋបាលគយរបស់ភាគីនីមួយៗ លើកលែងតែនីតិវិធីអនុវត្តច្បាប់និង សេចក្តីណែនាំការអនុវត្តផ្ទៃក្នុងផ្សេងទៀត

២. ភាគីនីមួយៗ ត្រូវជ្រើសតាំងកន្លែងទំនាក់ទំនងមួយ ឬច្រើនដើម្បីដោះស្រាយតម្រូវការពីបុគ្គលពាក់ព័ន្ធនឹងកិច្ចការគយ និងត្រូវដាក់បង្ហោះនៅក្នុងអ៊ីនធឺណែត និង/ឬ បោះពុម្ពផ្សាយនូវព័ត៌មានពាក់ព័ន្ធនីតិវិធីសម្រាប់ដំណើរការទំនាក់ទំនងស្នើសុំព័ត៌មាននេះ។

## មាត្រា ១៤

## ការពិគ្រោះយោបល់

១. រដ្ឋបាលគយនៃបណ្តាភាគី ត្រូវលើកទឹកចិត្តដល់ការពិគ្រោះយោបល់ជាមួយគ្នា នូវរាល់បញ្ហានានាដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្មទំនិញដែលបណ្តាលពីដំណើរការ ឬការអនុវត្តនៃជំពូកនេះ។

២. ការពិគ្រោះយោបល់នេះ ត្រូវធ្វើឡើងតាមរយៈមន្ត្រីទំនាក់ទំនងបង្គោលនៃរដ្ឋបាលគយដែលពាក់ព័ន្ធ។

៣. ភាគីនីមួយៗត្រូវផ្តល់ព័ត៌មាន របស់មន្ត្រីទំនាក់ទំនងបង្គោលនៃរដ្ឋបាលគយ និងផ្តល់ដំណឹងពីការធ្វើវិសោធនកម្មណាមួយ ទៅដល់ភាគីដទៃទៀតឱ្យបានឆាប់រហ័ស ។

## មាត្រា ១៥

## ឯកសារមុនទំនិញមកដល់

រដ្ឋបាលគយនៃគូភាគីត្រូវខិតខំប្រឹងប្រែងបង្កើតបទប្បញ្ញត្តិស្តីពី កន្លែងរក្សាទុកទំនិញ និងការចុះឈ្មោះ ឬការត្រួតពិនិត្យការប្រកាសទំនិញ និងឯកសារគាំទ្រនានា មុនពេលទំនិញមកដល់។

## មាត្រា ១៦

## ប្រតិបត្តិករសេដ្ឋកិច្ចស្របច្បាប់

១. រដ្ឋបាលគយនៃបណ្តាភាគីត្រូវខិតខំប្រឹងប្រែងបង្កើតកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចស្របច្បាប់ (AEO) ដើម្បីជំរុញការអនុលោមតាមច្បាប់ និងប្រសិទ្ធិភាពនៃការត្រួតពិនិត្យគយ។

២. រដ្ឋបាលគយនៃបណ្តាភាគីត្រូវខិតខំប្រឹងប្រែងធ្វើការដើម្បីឈានទៅការចុះកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនូវប្រតិបត្តិករសេដ្ឋកិច្ចស្របច្បាប់ (mutual recognition of AEO)។

## មាត្រា ១៧

## ការទូទាត់ឡើងវិញ ការសងត្រឡប់វិញ និងនិមុត្តធានា

១. សេចក្តីសម្រេចលើការទាមទារការទូទាត់ឡើងវិញនឹងត្រូវបានធ្វើឡើង និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលពាក់ព័ន្ធ ដោយគ្មានការពន្យារពេល ហើយការសងប្រាក់ពន្ធដែលបង់លើសត្រូវធ្វើឡើងឱ្យបានឆាប់ បន្ទាប់ពីមានការបញ្ជាក់ពីការទាមទារដោយត្រឹមត្រូវ

២. ការសងត្រឡប់វិញ ត្រូវផ្តល់ជូនវិញយ៉ាងឆាប់រហ័សបន្ទាប់ពីមានការបញ្ជាក់ពីការទាមទារដោយត្រឹមត្រូវ

៣. និមុត្តធានាត្រូវបានផ្តល់ជូន និងត្រូវធ្វើឡើងឱ្យឆាប់រហ័សបន្ទាប់ពីរដ្ឋបាលគយបញ្ជាក់ថា កាតព្វកិច្ចនានាដែលតម្រូវក្រោមច្បាប់និមុត្តធានាត្រូវបានបំពេញដោយត្រឹមត្រូវ។

## មាត្រា ១៨

## សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ

រដ្ឋបាលគយនៃបណ្តាភាគីត្រូវបង្កើត និងដំណើរការនូវសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ (PCA) សម្រាប់ការបញ្ចេញទំនិញរហ័ស និងបង្កើនការត្រួតពិនិត្យគយឱ្យកាន់តែប្រសើរ។

## មាត្រា ១៩

## ប្រវេសន៍កាលិក

អនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក រដ្ឋបាលគយនៃបណ្ដាភាគីត្រូវសម្រួលដល់ការធ្វើចរាចរនៃទំនិញ ក្រោមរបបប្រវេសន៍កាលិក ទៅតាមកម្រិតដែលអាចធ្វើទៅបាន។

## មាត្រា ២០

## ការសម្ងាត់វិជ្ជាជីវៈ

១. គ្មានចំណុចណាមួយក្នុងជំពូកនេះអាចត្រូវបានបកស្រាយ ដើម្បីទាមទារឱ្យភាគីណាមួយបញ្ចេញនូវព័ត៌មានសម្ងាត់ដែលៈ

ក. ផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុកនៃភាគីនោះ

ខ. ផ្ទុយទៅនឹងច្បាប់ និងបទប្បញ្ញតិក្នុងស្រុកណាមួយរបស់ភាគីនោះដែលអាចរួមមានច្បាប់ការពារភាពសម្ងាត់ផ្ទាល់ខ្លួន រឺកិច្ចការហិរញ្ញវត្ថុ និងគណនីរបស់អតិថិជនណាមួយនៃស្ថាប័នហិរញ្ញវត្ថុ

គ. រាំងស្ទះដល់ការអនុវត្តច្បាប់ ឬ

ឃ.បង្កើតភាពលម្អៀងនៃផលប្រយោជន៍ពាណិជ្ជកម្ម ដែលអាចរួមមានជំហរប្រកួតប្រជែងរបស់សហគ្រាសសាធារណៈ ឬឯកជនណាមួយ

២. ក្នុងករណីដែលភាគីណាមួយ ផ្ដល់ព័ត៌មានដល់ភាគីណាមួយទៀតស្របតាមជំពូកនេះ ហើយភាគីដែលផ្ដល់ព័ត៌មាននោះកំណត់ថាព័ត៌មាននោះជាព័ត៌មានសម្ងាត់ ភាគីទទួលបានព័ត៌មានត្រូវរក្សាភាពសម្ងាត់នេះឱ្យបាន ហើយប្រើប្រាស់ព័ត៌មាននោះសម្រាប់តែគោលបំណងដូចបានកំណត់ដោយភាគីផ្ដល់ឱ្យ និងមិនទម្លាយព័ត៌មាននោះដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីផ្ដល់ព័ត៌មានឱ្យនោះឡើយ។

## ជំពូកទី ២

## វិសោធនកម្មកិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មសេវា

១. អនុលោមទៅតាមកថាខណ្ឌ៣ នៃមាត្រា២៣ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា (TiS) កញ្ចប់ទី៣ នៃការប្ដេជ្ញាបើកចំហជាក់លាក់របស់ភាគីនីមួយៗ ដែលនឹងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងសេវា ត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ២ នៃពិធីសារនេះ។

២. ឧបសម្ព័ន្ធ២ នឹងត្រូវអនុវត្តចំពោះបណ្តាភាគីដែលបានដាក់ការប្តេជ្ញាបើកសេវារបស់ពួកគេរៀងៗខ្លួនជូនទៅឱ្យទៅអគ្គលេខាធិការអាស៊ាន។

## ជំពូកទី៣

## ការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគ

### មាត្រា ១

### ការជំរុញផ្នែកវិនិយោគ

មាត្រា ២០ នៃកិច្ចព្រមព្រៀងវិនិយោគ ត្រូវបានជំនួសដោយៈ

១. ភាគីនីមួយៗត្រូវធ្វើកិច្ចសហប្រតិបត្តិការបន្ថែមទៀតក្នុងការជំរុញ និងបង្កើនសកម្មភាពវិនិយោគដោយឈរលើមូលដ្ឋានកិច្ចព្រមព្រៀង ឬការរៀបចំដែលមានស្រាប់សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដើម្បីពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចក្នុងចំណោមបណ្តាភាគី។

២. បណ្តាភាគីនីមួយៗត្រូវលើកទឹកចិត្ត និងបង្កើនលក្ខខណ្ឌអំណោយផលសម្រាប់អ្នកវិនិយោគ និងការវិនិយោគរបស់ពួកគេ ដើម្បីជាផលប្រយោជន៍ទៅវិញទៅមក។

៣. បណ្តាភាគី ត្រូវធ្វើកិច្ចសហប្រតិបត្តិការក្នុងការជំរុញ និងបង្កើនការយល់ដឹងឱ្យកាន់តែប្រសើរនៃបណ្តាភាគី ដូចជាតំបន់វិនិយោគ តាមរយៈមធ្យោបាយណាមួយដូចខាងក្រោមៈ

ក. ដោយបង្កើនការវិនិយោគក្នុងចំណោមបណ្តាភាគី

ខ. ដោយរៀបចំសកម្មភាពជំរុញវិនិយោគ រួមមានព្រឹត្តិការណ៍ផ្គូផ្គងអាជីវកម្មនានា

គ. ដោយបង្កើនការបំពេញបន្ថែមនូវវិស័យឧស្សាហកម្ម និងបណ្តាញផលិតកម្ម

ឃ. ដោយរៀបចំ និងគាំទ្រដល់ការរៀបចំសន្និសីទ និងសិក្ខាសាលាស្តីពីឱកាសវិនិយោគនានា និងអំពីច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយវិនិយោគ និង

ង. ដោយធ្វើការផ្លាស់ប្តូរព័ត៌មានអំពីបញ្ហាផ្សេងៗដែលជាក្តីបារម្ភទៅវិញទៅមក ទាក់ទងនឹងការជំរុញ និងការសម្រួលវិនិយោគ។

## មាត្រា ២

## កិច្ចសម្រួលវិនិយោគ

មាត្រា ២១ នៃកិច្ចព្រមព្រៀងវិនិយោគ ត្រូវបានដាក់ជំនួសដោយ៖

១. ភាគីនីមួយៗ គួរខិតខំបង្កើតលក្ខខណ្ឌស្ថេរភាព អំណោយផល និងតម្លាភាពបន្ថែមទៀត ដើម្បីលើកទឹកចិត្តដល់ការវិនិយោគអោយកាន់តែច្រើនពីអ្នកវិនិយោគនៃភាគីម្ខាងទៀតនៅក្នុងដែនដីរបស់ខ្លួន ។

២. យោងទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់បណ្ដាភាគី បណ្ដាភាគីត្រូវសហការគ្នាដើម្បីសម្រួលដល់វិនិយោគនានារវាងបណ្ដាភាគី តាមរយៈ ភាគីចរចាដទៃទៀត:

ក. ដោយបង្កើតបរិយាកាសដែលចង់បានសម្រាប់គ្រប់គ្រងបែបបទនៃការវិនិយោគ

ខ. ដោយធ្វើឱ្យមាននីតិវិធីសាមញ្ញសម្រាប់ការអនុវត្ត និងការអនុម័តការវិនិយោគ

គ. ដោយជំរុញការផ្សព្វផ្សាយអំពីព័ត៌មានស្ដីពីការវិនិយោគរួមមាន ច្បាប់ វិធាន បទប្បញ្ញត្តិ គោលនយោបាយ និងនីតិវិធីនៃការវិនិយោគ និង

ឃ. ដោយប្រើប្រាស់ភ្នាក់ងារជំរុញការវិនិយោគដែលមានស្រាប់ ឬ ដោយបង្កើតមជ្ឈមណ្ឌលវិនិយោគច្រកចេញចូលតែមួយ ឬ យន្តការប្រហាក់ប្រហែលនៅក្នុងដែនដីនៃភាគីនីមួយៗជាម្ចាស់ផ្ទះតាមការចាំបាច់នឹងសមស្រប ដើម្បីផ្ដល់សេវាជំនួយ និងសេវាប្រឹក្សាយោបល់ដល់វិស័យពាណិជ្ជកម្មរួមទាំងការសម្រួលនៃការធ្វើអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតទាំងឡាយ។

## ជំពូក ៤

## ការធ្វើវិសោធនកម្មបទប្បញ្ញត្តិនានាទាក់ទងនឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសក្រោមកិច្ចព្រមព្រៀងក្របខណ្ឌ

មាត្រា ២(ធ), ៧ និង ៨(៤) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវលុបចោល ។ មាត្រា ៧ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌមានខាងក្រោម:

## មាត្រា ៧ (១)

## គោលការណ៍ជាមូលដ្ឋាន

១. បណ្ដាភាគីត្រូវអនុវត្តសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ពីការទទួលបាននូវផលប្រយោជន៍ទៅវិញទៅមកពីវិស័យពាណិជ្ជកម្ម និងវិនិយោគនៅក្នុងចំណោមភាគីទាំងអស់ ក្នុងបំណងជំរុញសហប្រតិបត្តិការសេដ្ឋកិច្ច ស្របទៅតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

២. ផ្អែកតាមធនធានដែលអាចរកបាន និងស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់ភាគីនីមួយៗ បណ្តាភាគីត្រូវខិតខំសម្រួលសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសនៅក្នុងចំណោមបណ្តាភាគី។ បណ្តាភាគីត្រូវស្វែងរកមធ្យោបាយ ដើម្បីពង្រីកសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសលើវិស័យដែលមានផលប្រយោជន៍ទៅវិញទៅមក បូករួមទាំងអនុសាសន៍ ដើម្បីបង្កើនសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសដែលមានស្រាប់ ព្រមទាំងអភិវឌ្ឍគំនិតផ្តួចផ្តើមថ្មីៗ។

៣. បណ្តាភាគីយល់ព្រមអនុវត្តកម្មវិធីកសាងសមត្ថភាពនិងជំនួយបច្ចេកទេស ជាពិសេសលើគម្រោងដែលបង្ហាញពីការចាំបាច់ជាក់លាក់ និងតម្រូវការដែលស្របទៅតាមវិស័យអាទិភាពនានា នៃសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស នៅក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន។ ការពិចារណាពិសេសនឹងត្រូវផ្តល់ទៅឱ្យប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ទាក់ទងនឹងការចូលរួមនៅក្នុងគម្រោងទាំងនេះ និងគម្រោងនានា ដែលបានស្នើឡើង។

## មាត្រា ៧ (២)

## វិស័យនានា នៃសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស

១. ដោយផ្អែកលើមូលដ្ឋាននៃការទទួលផលប្រយោជន៍ទៅវិញទៅមក បណ្តាភាគីត្រូវស្វែងរក និងអនុវត្តសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច ដែលមាននៅក្នុងវិស័យដូចតទៅ៖

(ក) បញ្ហានានាទាក់ទងនឹងពាណិជ្ជកម្ម

(ខ) កសិកម្ម ជលផល រុក្ខា និងផលិតផលព្រៃឈើ

(គ) ព័ត៌មាន និងបច្ចេកវិទ្យាទូរគមនាគមន៍

(ឃ) ការអភិវឌ្ឍធនធានមនុស្ស

(ង) វិនិយោគ

(ច) ពាណិជ្ជកម្មសេវាកម្ម

(ឆ) ទេសចរណ៍

(ជ) សហប្រតិបត្តិការឧស្សាហកម្ម

(ឈ) គមនាគមន៍

(ញ) កម្មសិទ្ធិបញ្ញា

(ដ) សហគ្រាសខ្នាតតូច និងមធ្យម

(ឋ) បរិស្ថាន និង

(ឌ) វិស័យផ្សេងៗទៀតដែលទាក់ទងទៅនឹងសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដែលបានឯកភាពគ្នាដោយភាគីទាំងអស់។

២. បណ្តាភាគី បានឯកភាពគ្នាផ្តោតលើសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដើម្បីគាំទ្រក្រុមការងារផ្សេងៗទៀតដែលស្ថិតនៅក្រោមគណៈកម្មាធិការរួមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ក្នុងការប្រើប្រាស់កិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងនានានៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌឱ្យបានកាន់តែល្អប្រសើរឡើង។

## មាត្រា ៧ (៣)

## ពាណិជ្ជកម្មអេឡិចត្រូនិចឆ្លងដែន (E-commerce)

១. បណ្តាភាគីបានទទួលស្គាល់កំណើនសេដ្ឋកិច្ច និងឱកាសដែលពាណិជ្ជកម្មអេឡិត្រូនិចបានផ្តល់ឱ្យ និងសារៈសំខាន់នៃការលើកកម្ពស់ការប្រើប្រាស់ និងការអភិវឌ្ឍ។

២. បណ្តាភាគីបានយល់ព្រមចែករំលែកព័ត៌មាន ជំនាញការ និងជំណើរការសន្ទនា លើបញ្ហាទាក់ទងទៅនឹងពាណិជ្ជកម្មអេឡិចត្រូនិច បូករួមបញ្ចូលទាំងច្បាប់ និងបទប្បញ្ញត្តិនានា វិធាននិងស្តង់ដារ និងការអនុវត្តឱ្យបានល្អប្រសើរ ក្នុងគោលបំណងដើម្បីបង្កើតបរិស្ថានដ៏អនុគ្រោះសម្រាប់អភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិច។

៣. ភាគីទាំងអស់ ត្រូវលើកទឹកចិត្តដល់ការចូលរួមពីសហគមន៍ជំនួញនានា និងពីភ្នាក់ងាររដ្ឋាភិបាល ដើម្បីទទួលបានផលប្រយោជន៍ពីវេទិកាពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce) ដើម្បីបង្កើនទំនាក់ទំនងពាណិជ្ជកម្ម និង វិនិយោគនៅក្នុងបណ្តាភាគីទាំងអស់។

៤. បណ្តាភាគី ត្រូវជំរុញសហប្រតិបត្តិការកសាងសមត្ថភាពតាមរយៈការគាំទ្រកម្មវិធីសិក្ខាសាលា និងបណ្តុះបណ្តាលស្តីពីពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce) ដើម្បីបង្កើនសមត្ថភាពសហគ្រាសមីក្រូ ខ្នាតតូច និងមធ្យម ដើម្បីពង្រីកចូលទៅក្នុងទីផ្សារក្នុងតំបន់ និងអន្តរជាតិ។

## មាត្រា ៧ (៤)

## ធនធានសម្រាប់សកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស

១. ជាមួយនឹងគោលបំណងក្នុងការធ្វើប្រតិបត្តិការជំពូកនេះ សកម្មភាពអាចមានទម្រង់ជាសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដែលរួមមានសិក្ខាសាលា ការបណ្តុះបណ្តាល គោលនយោបាយសន្ទនាសិក្សា ព្រមទាំងសកម្មភាពផ្សេងៗទៀតដែលបានឯកភាពពីបណ្តាភាគី។

២. បណ្តាភាគីត្រូវយល់ព្រមផ្តល់ប្រភពហិរញ្ញវត្ថុ សម្រាប់សកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសនានា នៅក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ពីធនធានអាស៊ាន-ចិនដែលមានស្រាប់ ឬពីធនធានផ្សេងទៀតដែលអាចរកបាននាពេលអនាគត ។

៣. បណ្តាភាគី បានយល់ព្រមបង្កើនសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដោយពន្លឿននីតិវិធីការវាយតម្លៃ និងអនុម័ត អភិវឌ្ឍការណែនាំដ៏ច្បាស់លាស់ និងសម្រួលការស៊ើបសួរលើគម្រោងសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ក្នុងបំណងជួយឱ្យអ្នកស្នើសុំគម្រោង ដើម្បីទទួលប្រើប្រាស់ប្រភពធនធានដែលរកបានអោយកាន់តែមានភាពប្រសើរឡើង។

## មាត្រា ៧ (៥)

## ការអនុវត្តនៃសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស

១. សកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសត្រូវមានការចូលរួមពីភាគីចិន និងប្រទេសសមាជិកអាស៊ានពីរយ៉ាងតិច ដែលបានបញ្ជាក់ថា សកម្មភាពទាំងនោះមានលក្ខណៈតំបន់ និងមានផលប្រយោជន៍ដល់បណ្តាប្រទេសជាសមាជិកអាស៊ាន និងចិន។

២. បណ្តាភាគីត្រូវអនុវត្តសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស តាមពេលវេលាដែលបានឯកភាពគ្នាទៅវិញទៅមក។

## មាត្រា ៧ (៦)

## ការដោះស្រាយវិវាទ

១. កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ នឹងមិនត្រូវយកមកអនុវត្តសម្រាប់ជំពូកនេះទេ។

២. រាល់វិវាទទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការបកស្រាយ ការប្រតិបត្តិ ឬការអនុវត្ត នៃជំពូកនេះ នឹងត្រូវដោះស្រាយដោយការអធ្យាស្រ័យល្អដោយបណ្តាភាគីទាំងអស់។

## ជំពូកទី ៥

## កម្មវិធីការងារបន្ទាប់

១. ស្របជាមួយនឹងមាត្រា១៧ នៃកិច្ចព្រមព្រៀងទំនិញ បណ្តាភាគីនឹងចូលរួមការចរចានានា ដើម្បីធ្វើសេរីការូបនីយកម្មពាណិជ្ជកម្មទំនិញបន្ថែមទៀត ផ្តែកលើកាលបរិច្ឆេទមួយ ដែលត្រូវឯកភាពគ្នាទៅវិញទៅមកដោយបណ្តាភាគី។ បណ្តាភាគី ត្រូវអនុវត្តដើម្បីបញ្ចប់ការចរចានេះក្នុងរយៈពេលពីរ(២)ឆ្នាំ ចាប់ពីថ្ងៃចាប់ផ្តើមការចរចា។

២. បណ្តាភាគី នឹងចូលរួមចរចាស្តីពីវិធានផលិតផលជាក់លាក់ (PSRs) ក្នុងគោលបំណងសម្រេច ឱ្យបានលទ្ធផលជាទីពេញចិត្តទៅវិញទៅមក ដែលនឹងធ្វើឱ្យមានភាពប្រសើរឡើងដល់ការប្រើប្រាស់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នៅក្នុងរយៈពេលមួយ(១)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ។

៣. បណ្តាភាគី ត្រូវបញ្ចប់ការពិភាក្សាទាំងឡាយពាក់ព័ន្ធនឹងការធ្វើសេរីភាវូបនីយកម្ម និងការការពារវិនិយោគក្នុងរយៈពេលបី(៣)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារ លើកលែងតែបណ្តាភាគីទាំងអស់យល់ព្រមផ្សេងពីនេះ។

## ជំពូក ៦

## អវសានប្បញ្ញត្តិ

### មាត្រា ១

### វិសោធនកម្ម

ពិធីសារនេះ អាចនឹងត្រូវបានធ្វើវិសោធនកម្មដោយមានការព្រមព្រៀងពីបណ្តាភាគីទាំងអស់ជាលាយលក្ខណ៍អក្សរ ហើយការធ្វើវិសោធនកម្មនេះនឹងចូលជាធរមានតាមកាលបរិច្ឆេទនោះ ឬ កាលបរិច្ឆេទដែលអាចត្រូវបានព្រមព្រៀងគ្នារវាងបណ្តាភាគីទាំងអស់។

### មាត្រា ២

### ការតម្កល់ទុក

សម្រាប់រដ្ឋសមាជិកអាស៊ាន ពិធីសារនេះ នឹងត្រូវដាក់តម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលត្រូវមានភារកិច្ចផ្តល់ជូនភ្លាមៗនូវឯកសារច្បាប់ចម្លងដែលបានបញ្ជាក់ត្រឹមត្រូវដល់រដ្ឋសមាជិកអាស៊ាននីមួយៗ។

### មាត្រា ៣

### ការចូលជាធរមាន

១. ភាគីនីមួយៗ ចាំបាច់ត្រូវជូនដំណឹងទៅអគ្គលេខាធិការអាស៊ាន អំពីការបញ្ចប់នីតិវិធីក្នុងស្រុករបស់

ខ្លួន[២]សម្រាប់ការចូលជាធរមាននៃពិធីសារនេះជាលាយលក្ខណ៍អក្សរ។ ពិធីសារនេះ នឹងត្រូវចូលជាធរមាននៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៦ បន្ទាប់ពីប្រទេសចិន និងប្រទេសសមាជិកអាស៊ានយ៉ាងហោចណាស់ចំនួនមួយ (១) បានជូនដំណឹងទៅអគ្គលេខាធិការអាស៊ានអំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនជាលាយលក្ខណ៍អក្សររួចហើយ។

២. ប្រសិនបើពិធីសារនេះ មិនទាន់បានចូលជាធរមាននៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៦ វានឹងត្រូវចូលជាធរមានហុកសិប (៦០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលប្រទេសចិន និងប្រទេសសមាជិកអាស៊ានយ៉ាងហោចណាស់មួយ (១) បានជូនដំណឹងទៅអគ្គលេខាធិការអាស៊ានអំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនជាលាយលក្ខណ៍អក្សររួចហើយ។

៣. បន្ទាប់ពីការចូលជាធរមាននៃពិធីសារនេះដោយអនុលោមទៅតាមកថាខណ្ឌទី១ ឬទី២ ពិធីសារនេះ នឹងត្រូវចូលជាធរមានសម្រាប់ភាគីដែលនៅសេសសល់រយៈពេលហុកសិប(៦០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងរបស់ខ្លួនទៅអគ្គលេខាធិការអាស៊ាន អំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនជាលាយលក្ខណ៍អក្សរ។

**ជាសក្ខីភាព** ហត្ថលេខាខាងក្រោម ដោយមានសិទ្ធិប្រទាន ផ្តល់ដោយរដ្ឋាភិបាលនៃរដ្ឋសមាជិករៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារនេះ។

ធ្វើនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥, ក្នុងច្បាប់ចម្លងជាភាសាអង់គ្លេស។

**សម្រាប់ប្រទេសប្រ៊ុយណេដារូសាឡឹម**

LIM JOCK SENG
រដ្ឋមន្ត្រីទី២ ក្រសួងការបរទេស និងពាណិជ្ជកម្ម

**សម្រាប់សាធារណរដ្ឋប្រជាមានិតចិន**

GAO HUCHENG
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រាប់ព្រះរាជាណាចក្រកម្ពុជា**

SUN CHANTHOL
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូនេស៊ី**

THOMAS TRIKASHIH LEMBONG
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

---

២ សម្រាប់ជាការបញ្ជាក់: ពាក្យ"នីតិវិធីផ្ទៃក្នុង" រួមមាន សច្ចាប័ន ការទទួលយក ការឯកភាពយល់ព្រមរបស់បណ្តាភាគីដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករៀងៗខ្លួន

សម្រាប់សាធារណរដ្ឋប្រជាប្រជាធិបតេយ្យប្រជាមានិតឡាវ

KHEMMANI PHOLSENA
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

សម្រាប់ប្រទេសម៉ាឡេស៊ី

MUSTAPA MOHAMED
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

សម្រាប់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

KAN ZAW
រដ្ឋមន្ត្រីសហភាប ក្រសួង ផែនការជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

សម្រាប់សាធារណរដ្ឋហ្វីលីពីន

GREGORY L. DOMINGO
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

សម្រាប់សាធារណរដ្ឋសឹង្ហបុរី

VIVIAN BALAKRISHNAN
រដ្ឋមន្ត្រីក្រសួងការបរទេស

សម្រាប់ព្រះរាជាណាចក្រថៃ

APIRADI TANTRAPORN
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់សាធារណរដ្ឋសង្គមនិយមវៀតណាម

APIRADI TANTRAPORN
រដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម

ASSOCIATION
OF SOUTHEAST
ASIAN NATIONS

The ASEAN Secretariat
70 A Jl. Sisingamangaraja
Jakarta 12110
Indonesia

Phone (62-21) 726 2991
(62-21) 724 3372
Fax: (62-21) 739 8234
(62-21) 724 3504

asean@secretariat.org
www.asean.org

## CERTIFYING STATEMENT

**Protocol to Amend the Framework Agreement on Comprehensive Economic Co-operation and Certain Agreements thereunder between the Association of Southeast Asian (ASEAN) and the People's Republic of China**

